# របាយការណ៍សង្ខេប
# ស្តីពីភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ
# ដោយឯកឧត្តម អ៊ុំ រាត្រី អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

ជាបឋម ខ្ញុំសូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាន នៅក្នុងសន្និសីទសារព័ត៌មាននាឱកាសនេះ។ ក្នុងនាមរដ្ឋបាលខេត្តបន្ទាយមានជ័យ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាមានកិត្តិយស និងក្តីសោមនស្សរីករាយដោយបានចូលរួមក្នុងសន្និសីទសារព័ត៌មាន នាឱកាសដ៏ថ្លៃថ្លានេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំនូវសន្និសីទសារព័ត៌មានស្តីពី « **ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ** » សូមអរគុណចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនសារព័ត៌មានទាំងអស់នៅទីនេះ។

ខ្ញុំសូមយកឱកាសនេះ សម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវចក្ខុវិស័យ និងគោលនយោបាយដ៏ត្រឹមត្រូវ រក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ ជាពិសេសរក្សាបាននូវកំណើនសេដ្ឋកិច្ច ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច អត្រាប្តូរប្រាក់មានស្ថិរភាព រួមចំណែកនូវការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេសបានជាបន្តបន្ទាប់ និងឈានទៅប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ នៅក្នុងបរិការណ៍បដិវត្តន៍ឧស្សាហកម្ម៤.០ ការរីកចំរើនផ្នែកវិទ្យាសាស្រ្ត និងបច្ចេកវិទ្យាសាកលបាន នឹងកំពុងលេចរូបរាង និងមានការវិវឌ្ឍយ៉ាងឆាប់រហ័ស។ បច្ចេកវិទ្យាឌីជីថលបាន និងកំពុងដើរតួនាទីជាស្នូល និងជាចលករនៅក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពសេដ្ឋកិច្ច និងសង្គម ដែលមានភាពសម្បូរបែបប្រសិទ្ធភាព និងផលិតភាពនៃប្រតិបត្តិការការងារ នៅជុំវិញការរស់នៅប្រចាំថ្ងៃរបស់យើង។ មិនត្រឹមតែប៉ុណ្ណោះ តាមរយៈការដាក់ចេញនូវ**គោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេចតេជោ** បានធ្វើឱ្យប្រទេសជាតិវិលមករកនូវសុខសន្តិភាពយ៉ាងពេញលេញបរិបូរណ៍ ធ្វើឱ្យប្រជាពលរដ្ឋទាំងអស់ទូទាំងប្រទេសទទួលបាននូវសិទ្ធិសេរីភាពក្នុងការដើរហើរ និងការប្រកបមុខរបរចិញ្ចឹមជីវិតដោយពុំមានការភ័យខ្លាច ដែលការណ៍នេះបានជួយជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស ក៏ដូចជានៅតាមមូលដ្ឋានរាជធានី ខេត្តទាំងអស់។ ក្នុងនោះខេត្តបន្ទាយមានជ័យ ក៏បានទទួលនូវផ្លែផ្កាយ៉ាងច្រើនរហូតមកដល់បច្ចុប្បន្ន ដោយបានប្រែក្លាយទឹកដីខេត្តពីស្ថានភាពលំបាក គ្មានការអភិវឌ្ឍន៍ក្នុងអំឡុងទសវត្សទី៨០ និងជាតំបន់សមរភូមិ មកជាតំបន់ដែលមានការអភិវឌ្ឍជាជំហានៗលើគ្រប់វិស័យ និងពីតំបន់ដែលមានមីន ទៅជាតំបន់សេដ្ឋកិច្ច ដែលមានរោងចក្រសហគ្រាសធំៗ ចូលវិនិយោគ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតគោរពរាយការណ៍ជូនដល់អង្គសន្និសីទ មេត្តាជ្រាបថា នៅក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ ខេត្តបន្ទាយមានជ័យ ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវកម្មវិធីនយោបាយយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ និងដោយមានការចង្អុលបង្ហាញណែនាំផ្ទាល់ពីសំណាក់

**ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី **ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាប្រធានក្រុមការងារចុះជួយមូលដ្ឋានខេត្តបន្ទាយមានជ័យ** និងថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នផ្សេងៗទៀត ខេត្តបន្ទាយមានជ័យបាននឹងកំពុងមានការរីកចំរើន និងប្រែប្រួលមុខមាត់ជាបន្តបន្ទាប់ផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងសមិទ្ធផល រូបវន្តជាច្រើន ជាពិសេស ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែបានលើកកម្ពស់ពីមួយថ្ងៃទៅមួយថ្ងៃ ជាមួយគ្នានេះរដ្ឋបាលខេត្តបន្ទាយមានជ័យបាននឹងកំពុងខិតខំ បង្កើនផលិតភាពការងាររដ្ឋបាល និងការបម្រើសេវារដ្ឋបាលសាធារណៈ ជូនប្រជាពលរដ្ឋកាន់តែបានល្អប្រសើរជាងមុន។

បន្ថែមលើកិច្ចខិតខំប្រឹងប្រែងខាងលើ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់រដ្ឋបាលឃុំ សង្កាត់ ប៉ុស្តិ៍នគរបាលឃុំ សង្កាត់ គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ បានចូលរួមអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាលច្បាប់ បទបញ្ញត្តិ ដែលញ៉ាំងឲ្យបរិយាកាស នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ប្រកបដោយសន្តិសុខ សុវត្ថិភាព សេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព និងមានភាពសម្ងាត់។ ការរៀបចំប្រព្រឹត្តទៅបានអាស្រ័យដោយសារ ប្រទេសជាតិមានស្ថេរភាពនយោបាយ មានសន្តិភាព សន្តិសុខ សុវត្ថិភាពក្នុងសង្គម និងមានការអភិវឌ្ឍ ទើបប្រទេសយើងបានរៀបចំការបោះឆ្នោតដោយរលូន និងទទួលបានលទ្ធផលល្អ ដូចយើងទទួលបានថ្មីៗកន្លងទៅនេះស្រាប់ ដែលមានការកោតសរសើរទាំងមតិជាតិ និងមតិអន្តរជាតិ។

**ឯកឧត្តម លោកជំទាវ**!

**ឆ្លៀតកិត្តិយស បងប្អូនអ្នកសារព័ត៌មានជាទីគោរពស្រឡាញ់រាប់អាន**!

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនអំពីស្ថានភាពទូទៅរបស់ខេត្តបន្ទាយមានជ័យ ជូនអង្គសន្និសីទឱ្យបានជ្រាបដូចតទៅ៖

## I. សេចក្តីផ្តើម ៖

ខេត្តបន្ទាយមានជ័យ ជាខេត្តមួយក្នុងចំណោមរាជធានី-ខេត្តទាំង២៥ទូទាំងប្រទេស ដែលមានចម្ងាយ ៣៦០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងកើតទល់នឹងខេត្តសៀមរាប ខាងលិចទល់នឹងព្រះរាជាណាចក្រថៃ លាតសន្ធឹងប្រវែង១៥៣គីឡូម៉ែត្រ ជាប់នឹងខេត្តស្រះកែវ និងខេត្តបូរីរ៉ាំ ខាងជើងទល់នឹងខេត្តឧត្តរមានជ័យ ខាងត្បូងទល់នឹងខេត្តបាត់ដំបង និងមាន**ច្រកទ្វារអន្តរជាតិចំនួន០២គឺ ច្រកអន្តរជាតិប៉ោយប៉ែត និងស្ទឹងបត់** និងច្រកទ្វារតំបន់ចំនួន**០២គឺ ច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ និងបឹងត្រកួន**។ ប៉ុន្តែចាប់តាំងពីវិបត្តិជាសកលនៃការឆ្លងរាលដាលជំងឺកូវីដ១៩ ច្រកទាំងអស់នេះត្រូវបានបិទជាបណ្តោះអាសន្ន រហូតមកដល់ខែឧសភា ឆ្នាំ២០២២ ទើបបើកដំណើរការជាប្រក្រតីវិញ បន្ទាប់ពីស្ថានភាពជំងឺកូវីដ១៩ មានភាពធូរស្រាល។

ខេត្តមានផ្ទៃដីសរុប ៦.៦៧៩គីឡូម៉ែត្រការ៉េ ចែកចេញជាក្រុង២ ស្រុក៧ ឃុំ៥៥ សង្កាត់១២ ចំនួនភូមិផ្លូវការ៦៥៩ភូមិ មានចំនួនគ្រួសារ*១៩៨.៩២៦គ្រួសារ* ចំនួនមនុស្សរាយ*៨០០.១៨៨នាក់* ក្នុងនោះស្រី *៤០៥.៣២៤នាក់* ជនជាតិខ្មែរឥស្លាម ចំនួន *៥៦.៨៥៦នាក់* មុខរបរសំខាន់របស់ប្រជាពលរដ្ឋ*៨៥% ជាកសិករ ១០%ជាអាជីវករ និងពាណិជ្ជករ និង៥% ប្រកបមុខរបរផ្សេងៗ*។

## II. សមិទ្ធផលសំខាន់ៗ ៖

**១.សមិទ្ធផលឯកជន៖** កម្មវិធីឧបត្ថម្ភសាច់ប្រាក់ និងសម្ភារៈដល់ប្រជាពលរដ្ឋជួបការលំបាកទទួលបានការឧបត្ថម្ភពីរាជរដ្ឋាភិបាល ជាពិសេស គឺជាផលប្រយោជន៍នៅក្នុងព្រឹត្តិការណ៍ដូចជា៖

- ❖ គ្រួសារដែលឆ្លងជំងឺកូវីដ-១៩ចំនួន ១.២០៦គ្រួសារ ទឹកប្រាក់៣៣៧.៧៨៣.៣០០រៀល **(បីរយសាមសិបប្រាំពីរលាន ប្រាំរយរយប៉ែតសិបបីពាន់ បីរយរៀលគត់)**
- ❖ ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ សរុបចំនួន៩.៤៣០នាក់ ទឹកប្រាក់៤.៣២៩.២៨០.០០០រៀល **(បួនប៊ីលាន បីរយម្ភៃប្រាំបួនលាន ពីររយប៉ែតសិបពាន់រៀលគត់)**។
- ❖ គ្រួសារដែលស្លាប់ដោយសារជំងឺកូវីដ-១៩ចំនួន ៩៧គ្រួសារ ទឹកប្រាក់៧០.០៨៨.៥០០រៀល **(ចិតសិបលាន ប៉ែតសិបប្រាំបីពាន់ ប្រាំរយរៀលគត់)**
- ❖ គ្រួសារក្រីក្រដែលទទួលបានប្រាក់ឧបត្ថម្ភសរុបចំនួន៣១.៩១២គ្រួសារ ទឹកប្រាក់១២១.១១៤.៥៦៤.០០០៛ **( មួយរយម្ភៃមួយប៊ីលាន មួយរយដប់បួនលាន ប្រាំរយហុកសិបបួនពាន់រៀលគត់ )** គិតជាដុល្លារ ៣០.២៧៨.៦៤១$ **(សាមសិបលាន ពីររយចិតសិបប្រាំបីពាន់ ប្រាំមួយរយសែសិបមួយដុល្លារ)** ក្នុងនោះមានគ្រួសារក្រីក្រ១ ចំនួន១១.៨៨៦គ្រួសារ ទឹកប្រាក់ ៥២.៥១៨.៩៥២.០០០រៀល (**ហាសិបពីរប៊ីលាន ប្រាំរយដប់ប្រាំបីលាន ប្រាំបួនរយហាសិបពីរពាន់រៀលគត់**) គ្រួសារក្រីក្រ២ ចំនួន២០.០២៦គ្រួសារ ទឹកប្រាក់៦៨.៥៩៥.៦១២.០០០រៀល( **ហុកសិបប្រាំបីប៊ីលាន ប្រាំរយកៅសិបប្រាំលាន ប្រាំមួយរយដប់ពីរពាន់រៀលគត់**)។
- ❖ គ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណាមានចំនួន១៥.២៩៦គ្រួសារ ទឹកប្រាក់ចំនួន ២.៣១១.៥៩៨.៨០០រៀល (**ពីប៊ីលាន បីរយដប់មួយលាន ប្រាំរយកៅសិបប្រាំបីពាន់ ប្រាំបីរយរៀលគត់** )(អំឡុងពេលជំងឺកូវីដ១៩រីករាលដាលខ្លាំង)។
- ❖ គ្រួសារងាយរងហានិភ័យប៉ះពាល់ធ្ងន់ធ្ងរដោយគ្រោះទឹកជំនន់ចំនួន១៩.៧២៣គ្រួសារ ទឹកប្រាក់ចំនួន ៣.១៩១.២៤៨.០០០រៀល (**បីប៊ីលាន មួយរយកៅសិបមួយលាន ពីររយសែសិបប្រាំបីពាន់រៀលគត់** )។

**២.សមិទ្ធផលសាធារណ:៖** ខេត្តបន្ទាយមានជ័យមានសក្តានុពលពឹងផ្អែកលើវិស័យកសិកម្មជាចម្បងមុខរបរសំខាន់របស់ប្រជាពលរដ្ឋ **៨៥%**ជាកសិករ **10%**ជាអាជីវករ និងពាណិជ្ជករ និង**៥%** ប្រកបរមុខរបរផ្សេងៗ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនអំពីភាពជោគជ័យរយៈពេល***៥ឆ្នាំកន្លងមក*** របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ មានដូចខាងក្រោម៖

**២.១.ការខារគ្រប់គ្រងរដ្ឋបាល៖** ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) ការផ្តល់សេវារដ្ឋបាលទាំង១៤ ការងារ/វិស័យ ជូនប្រជាពលរដ្ឋ តាមរយៈអង្គភាពច្រកចេញចូលតែមួយខេត្តសរុបចំនួន២១៤.៣៧០សេវា និងទទួលចំណូលសរុប១៧.៩២៦.០៤៨.៩០០រៀល **(ដប់ប្រាំពីរប៊ីលាន ប្រាំបួនរយម្ភៃប្រាំមួយលាន សែសិបប្រាំបីពាន់ ប្រាំបួនរយរៀលគត់)**។ បច្ចុប្បន្នរដ្ឋបាលខេត្ត មានកន្លែងផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយខេត្ត ការិយាល័យច្រកចេញចូលតែមួយគ្រប់ក្រុង ស្រុកទាំង០៩ និងយន្តការច្រកចេញចូលតែមួយគ្រប់ឃុំ សង្កាត់ទូទាំងខេត្ត។

ក្នុងរយៈពេល៥ឆ្នាំ កន្លងមកនេះខេត្តបានអនុវត្តគម្រោងកម្មវិធី៣ឆ្នាំរំកិល ដោយសម្រេចបាន ចំនួន១៦៧ គម្រោង ថវិកាចំណាយលើគម្រោងវិនិយោគសរុបចំនួន២៣៤.៨៥៣.៥៥០.៥០០រៀល (**ពីរទ្រីលាន សាមសិបបួនប៊ីលាន ប្រាំបីរយហាសិបបីលាន ប្រាំរយហាសិបពាន់ ប្រាំរយរៀលគត់** )។

**២.២.អំពីការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណ: និងសុវត្ថិភាពសង្គម៖**

សភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គមទាំងផ្ទៃក្នុងខេត្ត និងតាមតំបន់ព្រំដែន ជាទូទៅមានលក្ខណៈល្អប្រសើរ ដោយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ សមត្ថកិច្ចពាក់ព័ន្ធ បានយកចិត្តទុកដាក់ទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំ សង្កាត់ មានសុវត្ថិភាព ក្នុងការបង្ការបង្ក្រាប និងទប់ស្កាត់បទល្មើសផ្សេងៗ ពិសេសការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារជាដើម។

លើការងារសន្តិសុខព្រំដែន ខេត្តរក្សាបាននូវបូរណភាព និងអធិបតេយ្យភាពជាតិ ព្រមទាំង ប្រែក្លាយតំបន់ព្រំដែនជាព្រំដែនសន្តិភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។ ជាក់ស្តែងបទល្មើសព្រហ្មទណ្ឌនៅទូទាំងខេត្តចំនួន*៤១៨ករណី បង្ក្រាបបានចំនួន៣៤២ករណី បទល្មើសគ្រឿងញៀនបង្ក្រាបបានចំនួន១.៩០៥ករណី បទល្មើសជួញដូរមនុស្សបង្ក្រាបបានចំនួន៨៣ករណី និងជួញដូរផ្លូវភេទបង្ក្រាបបានចំនួន២៦ករណី ល្បែងស៊ីសងបង្ក្រាបបានចំនួន២៥៦ករណី និងក្មេងទំនើងបង្ក្រាបបានចំនួន១០៦ករណី។*

ជាមួយគ្នានេះ ខេត្តបានរក្សាទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អរវាងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ តាមរយៈការជួបប្រជុំពិភាក្សាដើម្បីផ្លាស់ប្តូរព័ត៌មាន និងបង្កើនកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ។ ទន្ទឹមនេះ កងកម្លាំងរក្សាសន្តិសុខព្រំដែន បានសហការជាមួយសមត្ថកិច្ចថៃទទួលពលករត្រឡប់មកវិញសរុបចំនួន ១១០.៣៦២នាក់។

ចំពោះលទ្ធផលនៃការប្រឡងប្រណាំងភូមិ ឃុំ សង្កាត់មានសុវត្ថិភាពក្នុងឆ្នាំ២០២២នេះ ឃុំ សង្កាត់បានចំណាត់ថ្នាក់លេខ១ មានចំនួន៥៤ឃុំ សង្កាត់ និងឃុំ សង្កាត់បានទទួលចំណាត់ថ្នាក់លេខ២ មានចំនួន១២ ឃុំ សង្កាត់ និងចំណាត់ថ្នាក់លេខ៣ មានចំនួន ០១ឃុំ សង្កាត់។

**២.៣.ការអនុវត្តគម្រោងអភិវឌ្ឍន៍ខេត្ត ២០១៨-២០២២ (ចំនួន១៦៧គម្រោង សរុបទឹកប្រាក់ចំនួនៈ ២៣៤ ៨៥៣.៥៥០.០០០ រៀល ( ពីររយសាមសិបបួនប៊ីលាន ប្រាំបីរយហាសិបបីលាន ប្រាំរយហាសិបពាន់រៀលគត់ ))**

-ការងារជួសជុលនិងស្ថាបនាផ្លូវបេតុងកម្រាស់១៥សង់ទីម៉ែត្រ មានចំនួន ៤៤គម្រោង ចំនួន៤៨ខ្សែ សរុបប្រវែង៣៩.៧៧៨ម៉ែត្រ។

-ការងារជួសជុលផ្លូវក្រាលកៅស៊ូDBSTមានចំនួន ១៤គម្រោង ចំនួន១៤ខ្សែ សរុបប្រវែង២៦.៥៧០ម៉ែត្រ។

-ការងារជួសជុលផ្លូវក្រាលគ្រួសក្រហមមានចំនួន ៨គម្រោង ចំនួន ០៦ខ្សែ សរុបប្រវែង៣២.៦៩៤ម៉ែត្រ។

-ការងារជួសជុលដាក់លូជ្រុង,លូQ100,លូQ80 , មានចំនួន ៤២គម្រោង ចំនួន២៥៤១កង់ សរុបប្រវែង៥.១០៣ ម៉ែត្រ។

-ការងារស្តាលូ និងប្រឡាយ ចំនួន ៤គម្រោង មាន៤កន្លែង សរុបប្រវែង៨.០៤៥ម៉ែត្រ។

-ការងាររៀបចំបណ្តាញអគ្គិសនីបំភ្លឺសាធារណៈ និងបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈមានចំនួន៥៥ គម្រោង ចំនួន៩៣៥ដើម។

**២.៤.ការប្រលងប្រណាំងក្រុងស្អាត និងទីក្រុងឆ្លាតវៃ៖**

**ពានរង្វាន់ក្នុងប្រទេស៖** ខេត្តបន្ទាយមានជ័យទទួលបានពានរង្វាន់រួមមានៈ ចលនាប្រលងប្រណាំងបង្គន់សាធារណៈកម្ពុជាលើកទី២ក្នុងឆ្នាំ២០២០ ( **ចំណតរថយន្តស៊ូជីង ទទួលបានស្នាមញញឹម៣ - រមណីយដ្ឋានសួនស្នេហ៍ជនបទ ទទួលបានស្នាមញញឹម៣ - រមណីយដ្ឋានប្រាសាទបន្ទាយឆ្មារទទួលបានស្នាមញញឹម៣ - សួនមានជ័យទទួលបានស្នាមញញឹម២** ), ការប្រលងប្រណាំងសហគមន៍ទេសចរណ៍ ល្អបំផុតខេត្តបន្ទាយមានជ័យបានទទួលជ័យលាភី៣ឆ្នាំជាប់គ្នា ( ឆ្នាំ២០១៧-២០១៨, ២០១៨-២០១៩ និង ២០១៩-២០២០ ), ការប្រលងប្រណាំងទីក្រុងស្អាតលើកទី២ឆ្នាំ២០២១ ក្រុងចំនួន២ ដែលបានជាប់ជ័យលាភីទទួលបានផ្កាឈូក២ទងគឺ ក្រុងសិរីសោភ័ណ និងក្រុងប៉ោយប៉ែត, ការប្រលងប្រណាំងទីក្រុងស្អាតលើកទី៣ ឆ្នាំ២០២២ ក្រុងសិរីសោភ័ណ និងក្រុងប៉ោយប៉ែត បានទទួលជ័យលាភីផ្កាឈូក២ទង នៅក្រសួងទេសចរណ៍ រាជធានីភ្នំពេញ។ ខេត្តទទួលបានពានរង្វាន់សហគមន៍ទេសចរណ៍ឆ្នើមឆ្នាំ២០២២ នៅរាជធានីភ្នំពេញ

និងពានរង្វាន់ជ័យលាភីមាសប្រចាំឆ្នាំ២០២២ផ្នែកអារាមមេត្រីភាពបរិស្ថាន(វត្តប្រាសាទស្រះកណ្ដាល (ខ្ពស់) ស្រុកព្រះនេត្រព្រះ នៅក្រសួងបរិស្ថានរាជធានីភ្នំពេញ ។

**ពានរង្វាន់ក្រៅប្រទេស៖** ខេត្តបានទទួលពានរង្វាន់រួមមានៈ ពានរង្វាន់ទេសចរណ៍ប្រកបដោយនិរន្តរភាពអាស៊ានឆ្នាំ២០២០ នៅប្រទេសវៀតណាម, TO DO Award Contest ទេសចរណ៍ទំនួលខុសត្រូវសង្គមឆ្នាំ២០២០ នៅប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ២០២១, ពានរង្វាន់ស្ដង់ដារទេសចរណ៍ផ្អែកលើសហគមន៍អាស៊ានឆ្នាំ២០១៩-២០២១ នៅប្រទេសព្រុយណេ និងជ័យលាភីផ្ទះស្នាក់អាស៊ាន **យឿន ស្រីមុំ** ស្តង់ដារឆ្នាំ ២០១៩-២០២១ ប្រទេសវៀតណាម។

## ២.៥.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំសោភ័ណភាពទីក្រុង ទីប្រជុំជន (ក្របខណ្ឌ អភិវឌ្ឍន៍ ក្រុង ស្រុក)៖

មកដល់បច្ចុប្បន្ន ផ្លូវកៅស៊ូតាមទីប្រជុំជនទាំងក្រុង ស្រុកមានប្រវែងសរុប៣៧៧គ.ម ផ្លូវបេតុងមានប្រវែង១៦៣គ.ម និងផ្លូវក្រាលក្រួស៤៧៦គ.ម សាងសង់លូមូលចំនួន១៦.២៤៦កន្លែង និងលូប្រអប់ចំនួន៤.៩០០កន្លែង រៀបចំប្រព័ន្ធលូរំដោះទឹក និងដាក់រ៉ឺហ្កាបានប្រវែង៥,៦៩៧ម៉ែត្រ សាងសង់ប្រព័ន្ធលូទឹកស្អុយចំនួន៧៤កន្លែង និងមានស្ថានីយ៍ប្រព្រឹត្តកម្មទឹកស្អុយចំនួន១ស្ថានីយ៍ ស្ពារប្រព័ន្ធលូក្នុងទីប្រជុំជន ចំនួន៣៤.០២៣ម៉ែត្រ និងស្ពារប្រឡាយទឹកស្អុយតាមទីប្រជុំជនផ្សារចំនួន៤៤.៤២០ម៉ែត្រ។ ភ្លើងបំភ្លឺតាមដងផ្លូវសរុប មានចំនួន២.៥៣៨បង្គោល ផ្សារទំនើប មានចំនួន៣កន្លែង សេវាដឹកជញ្ជូនសាធារណៈចំនួន ០៤ ភ្លើងស្តុប មានចំនួន១១ទីតាំង សួនសាធារណៈមានចំនួន៩កន្លែង ក្រុមហ៊ុនប្រមូលសំរាម និងទីលានចាក់សំរាម មានចំនួន៩កន្លែង រៀបចំផ្លូវថ្មើរជើង សរុបប្រវែង៤៧៥.៥៤គ.ម ចាក់បេតុងការពារច្រាំងស្ទឹង និងទំនប់ ១.៤៥០ម៉ែត្រ។

## ២.៦.វិស័យកសិកម្ម៖

ខេត្តបន្ទាយមានជ័យគឺជាខេត្តដែលមានភាពល្បីល្បាញលើវិស័យកសិកម្ម និងជាប់ឈ្មោះជាខេត្តជង្រុកស្រូវនៃព្រះរាជាណាចក្រកម្ពុជា។ មានប្រព័ន្ធធារាសាស្ត្រដែលបានចុះបញ្ជីសារពើភ័ណ្ឌ(CISIS) សរុបចំនួន៨៧ ប្រព័ន្ធ (ខ្នាតតូច ៦ប្រព័ន្ធ ខ្នាតមធ្យម ៧៥ប្រព័ន្ធ និងខ្នាតធំ ៦ប្រព័ន្ធ) ស្ថិតនៅរាយប៉ាយតាមបណ្ដា ក្រុង ស្រុក ទូទាំងខេត្ត ដែលអាចធ្វើការស្រោចស្រពបានលើផ្ទៃដីចំនួន៦៣.២០២ហិកតា ផ្ទៃដីស្រូវវស្សាដែលទទួលបានពីប្រព័ន្ធស្រោចស្រពចំនួន២៧.៩៨៤ហិកតា ផ្ទៃដីស្រូវប្រាំងចំនួន៣៥.២១៨ហិកតា។

ផ្ទៃដីដាំដុះស្រូវសរុបចំនួន៣០៥.០៣៥ហិកតា ដែលទទួលបានបរិមាណសរុបចន្លោះពី៩សែនតោនទៅ១លានតោនក្នុងមួយឆ្នាំ ក្នុងនោះ ស្រូវវស្សា**៧៦៨ ៧៩៥**តោនក្នុង១ឆ្នាំ ស្រូវប្រាំង**២៥១ ៣៦៨**តោនក្នុង១ឆ្នាំ។រីឯផ្ទៃដីដំណាំឧស្សាហកម្មសរុបមានចំនួន១២២.៧៩២ហិកតា ក្នុងនោះដំឡូងមី១០២ ៩៥៥ហិកតា ស្វាយចន្ទី៣ ៥៨៩ហិកតា ពោតក្រហម១៣ ៧៦១ហិកតា អំពៅ៥០១ហិកតា សណ្ដែកបាយ៥១ហិកតា ដំណាំបន្លែមានចំនួន៣.៥៣៨ហិកតា ,ដំណាំរួមផ្សំ មានចំនួន៥.៧៣៥ហិកតា។ ក្នុងរយៈពេល៥ឆ្នាំនេះ បរិមាណស្រូវសរុបចំនួន ៤.៨១៥.៤៦៣តោន ពោតក្រហមចំនួន ៣៩១.៦៣០តោន ដំឡូងមី ១០.២៨២.២១៨តោន អំពៅ ៧៤.៨៨១តោន។

*ការងារគ្រឿងយន្តកសិកម្ម* មានត្រាក់ទ័រចំនួន៣.៩១៣គ្រឿង, គោយន្តចំនួន៤៥.៩៦៥គ្រឿង, ម៉ាស៊ីនច្រូតចំនួន៨០២គ្រឿង, រោងម៉ាស៊ីនកិនស្រូវ និងកែច្នៃមានចំនួន៣៥៨កន្លែង, ម៉ាស៊ីនសម្ងួតមានចំនួន១៥កន្លែង ដែលមានសមត្ថភាពសម្ងួត ចំនួន២៣៥.៨០០តោនក្នុងមួយឆ្នាំ។

*ការជំរុញការចិញ្ចឹមសត្វ* ជារួមមានគោក្របីចំនួន១៣២.៤៦០ក្បាល, ជ្រូកសរុបចំនួន៤៦.៨៦៩ក្បាល និងបក្សីសរុបចំនួន១.៦៦៧.៣៩៩ក្បាល។ ក្នុងនោះមានកសិដ្ឋានចិញ្ចឹមលក្ខណៈពាណិជ្ជកម្ម ចំនួន៨៣កសិដ្ឋាន ដែលមានសត្វ ចំនួន៥៨៥.៥៨៧ក្បាល ក្នុងនោះគោចំនួន១៤កសិដ្ឋាន ស្មើ២.០១៣ក្បាល, ជ្រូកមានចំនួន ២០កសិដ្ឋាន ស្មើនឹង២៥.០៧៤ក្បាល និងបក្សី (មាន់ ទា) ចំនួន៤៩កសិដ្ឋាន ស្មើនឹង៥៥៨.៥០០ក្បាល ។

*ការអភិវឌ្ឍន៍វារីវប្បកម្ម* ក្នុងរយៈពេល៥ឆ្នាំនេះ ផលនេសាទសរុបទទួលបានចំនួន ១៣០.៣០៨ តោន ដែលក្នុងនោះ បានកែច្នៃផលនេសាទសម្រាប់ធ្វើការនាំចេញចំនួន ២.១៨៥ តោន។

*សហគមន៍កសិកម្មមាន* ចំនួន៤៩សហគមន៍ សមាជិកសរុបចំនួន៤.៨០៥នាក់ និងមានទុនសរុបចំនួន ១.៨១៤.៤០៦.៣០០រៀល។ សហគមន៍នេសាទចំនួន១៩សហគមន៍ ដែលមានសមាជិកសរុបចំនួន ១២.០៩៣នាក់។ សហគមន៍ព្រៃឈើមានចំនួន៩សហគមន៍ មានលើផ្ទៃដីចំនួន៣.៥៤៤ហិកតា គ្រួសារចំនួន ១,៨០៣គ្រួសារ មនុស្សរាយចំនួន៤.៨៣៩នាក់ ។

## ២.៧-វិស័យធនធានទឹក៖

ដើម្បីជំរុញឱ្យវិស័យកសិកម្មមានការរីកចម្រើន ខេត្តបានខិតខំស្តារ និងកែលំអប្រព័ន្ធអាងទឹកជាច្រើនកន្លែង ក្នុងការរក្សាទឹកទុកសម្រាប់ការស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗ ក្នុងនោះ ៖

-បានជួសជុលអាងទឹកចំនួន១១អាង ប្រវែង៤២,៨០០ម៉ែត្រ

-បានសាងសង់សំណង់ទ្វារទឹកកាត់ស្ទឹងចំនួន០៧កន្លែង

-បានជួសជុល ស្តារប្រឡាយមេចំនួន៥៨ខ្សែ ប្រវែង៣៩៣.០០០ម៉ែត្រ

-បានជួសជុល ស្តារប្រឡាយរងចំនួន១៨២ខ្សែ ប្រវែង៨៣០.៤០០ម៉ែត្រ

-បានជីកប្រឡាយជើងក្អែបចំនួន៨៣៧ខ្សែ ប្រវែង១.២៥៦.៣០០ម៉ែត្រ

-បានតំឡើងស្ថានីយ៍បូមទឹកចំនួន០៣កន្លែង និងស្តារស្ទឹងស្វាយចេក ប្រវែង១៦.០០០ម៉ែត្រ

-បានចាក់បេតុងក្លឹអាងត្រពាំងថ្ម ប្រវែង១៧.០០០ម៉ែត្រ

**គម្រោងដែលគាំទ្រដោយកូរ៉េ ៖**

**-ស្រុកអូរជ្រៅ ឃុំសឹង្ហ ប្រព័ន្ធអាងទឹកកន្សែង ជីកប្រឡាយមេចំនួន០២ខ្សែ ប្រវែង៣៥ ៥៧០ម៉ែត្រ និងជួសជុលក្លឹទំនប់ប្រវែង៧ ១២០ម៉ែត្រ(កំពុងសិក្សាគម្រោង)**

**-ក្រុងប៉ោយប៉ែត សង្កាត់និមិត្ត ប្រព័ន្ធអាងទឹកពង្រ ជីកប្រឡាយមេចំនួន០១ខ្សែ ប្រវែង១៦.៤២០ម៉ែត្រ និងជួសជុលក្លឹទំនប់ប្រវែង៧ ០១០ម៉ែត្រ(អនុវត្តបាន១៥%)**

**-ស្រុកម៉ាឡៃ ឃុំទួលពង្រ ប្រព័ន្ធអាងទឹករាំងហែង ជីកប្រឡាយមេចំនួន០២ខ្សែ ប្រវែង៣៥ ៦១០ម៉ែត្រ (កំពុងសិក្សាគម្រោង)និងលើកក្លឹទំនប់ប្រវែង៦ ២៣០ម៉ែត្រ(អនុវត្តបាន១៥%)**

**-ស្តារស្ទឹងស្វាយចេក ប្រវែង៣២គ.ម (បានអនុវត្តរួច១៦គ.ម និងកំពុងដាក់ដេញថ្លៃចំនួន១៦គ.ម)**

សមិទ្ធផលនៃប្រព័ន្ធធារាសាស្ត្រដែលផ្តល់លទ្ធភាពក្នុងការស្រោចស្រព ទាំងតូចទាំងធំចំនួន៨៧ក្នុងនោះបែងចែកជា ***ខ្នាតធំ០៦ប្រព័ន្ធ ខ្នាតមធ្យម៧៥ប្រព័ន្ធ និងខ្នាតតូច០៦ប្រព័ន្ធ*** ដែលខ្នាតធំស្រោចស្រពចាប់ពី ៥.០០០ហ.តឡើង, ខ្នាតមធ្យមស្រោចស្រពក្រោម៥.០០០ហ.ត និងខ្នាតតូចស្រោចស្រពចាប់ពី៥០០ហ.តចុះ។

## ២.៨.វិស័យពាណិជ្ជកម្ម និងវិនិយោគៈ

ក្រុមហ៊ុនវិនិយោគ និងរោងចក្រធំៗនៅក្នុងខេត្ត មានដូចជាៈ

-ក្នុងឆ្នាំ២០២២ ខេត្តមានតំបន់សេដ្ឋកិច្ចពិសេសចំនួន៣កន្លែង និងសួនឧស្សាហកម្មចំនួន១កន្លែងៈ

- តំបន់សេដ្ឋកិច្ចពិសេសអូរនាង មានរោងច្រកចំនួន៤កន្លែង
- តំបន់សេដ្ឋកិច្ចពិសេសសានកូ មានរោងច្រកចំនួន១០កន្លែង
- តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែតូយ៉ាល់គ្រុប មានរោងច្រកចំនួន១កន្លែង
- សួនឧស្សាហកម្មក្រុងសិរីសោភ័ណ មានរោងច្រកចំនួន១កន្លែង
- **តំបន់សេដ្ឋកិច្ចពិសេសមិនដំណើរការចំនួន១គឺ តំបន់សេដ្ឋកិច្ច លី អ៊ុតនី**

-មានរោងចក្រសរុបចំនួន២២រោងចក្រ **និង**សហគ្រាសធនតូច និងមធ្យម និងសិប្បកម្មមានចំនួន១.២៣៨កន្លែង នៅក្នុងដែនសមត្ថកិច្ចរដ្ឋបាលខេត្ត យើងមានសហគ្រាសគ្រឹះស្ថាន សរុបចំនួន២៨១ ដែលមានកម្មករនិយោជិតសរុបចំនួន២៦,៥៦០នាក់។ ដោយខេត្តមានព្រំប្រទល់ជាប់នឹងព្រះរាជាណាចក្រថៃ ដែលជាកត្តាអំណោយផល ដល់ការដោះដូរ-ដឹកជញ្ជូនទំនិញ ការធ្វើពាណិជ្ជកម្ម ការធ្វើដំណើរចេញ-ចូល ទេសចរណ៍ ការធ្វើកិច្ចសហប្រតិបត្តិការ និងបានជួយជំរុញដល់កំណើនសេដ្ឋកិច្ចរបស់ខេត្តផងដែរ។ ទំនិញនាំចេញរបស់ខេត្តបន្ទាយមានជ័យ ទៅប្រទេសថៃភាគច្រើនជាប្រភេទកសិផល ដូចជា ដំឡូងមី,ម្ទេសក្រៀម,អពៅ,ពោតក្រហម, ស្វាយចន្ទី, ស្រូវ...។ល។

## ២.៩.វិស័យទេសចរណ៍ៈ

ខេត្តបន្ទាយមានជ័យជាខេត្តមួយដែលមានទីតាំងប្រវត្តិសាស្ត្រ, វប្បធម៌, រមណីយដ្ឋានជាច្រើន ដែលជាសក្តានុពល ក្នុងការទាក់ទាញភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិ មកទស្សនា សម្រាកលំហែកាយ និងកំសាន្ត នៅតាមបណ្តាតំបន់ទេសចរណ៍នានាក្នុងខេត្ត។

ជាមួយគ្នានេះ ខេត្តមានសណ្ឋាគារចំនួន២៨កន្លែង ផ្ទះសំណាក់ចំនួន៨៣កន្លែង ផ្ទះស្នាក់ (Home Stay ) ចំនួន០៦កន្លែង ភោជនីយដ្ឋានចំនួន៣០កន្លែង អាហារដ្ឋានចំនួន៧៨កន្លែង ដែលកំពុងដំណើរការផ្តល់ជូនសេវាស្នាក់នៅ និងចំណីអាហារប្រកបដោយភាពកក់ក្តៅ និងមានគុណភាពជូនដល់ភ្ញៀវជាតិ និងអន្តរជាតិ។ ខេត្តមានសហគមន៍ទេសចរណ៍មាន**០១**កន្លែង (សហគមន៍ទេសចរណ៍បន្ទាយឆ្មារ) រមណីយដ្ឋានទេសចរណ៍មានចំនួន១៣កន្លែង ក្នុងនោះរួមមានៈ រមណីយដ្ឋានវប្បធម៌ និងប្រវត្តិសាស្ត្រចំនួន០២កន្លែង, រមណីយដ្ឋានកែច្នៃធម្មជាតិ និងប្រវត្តិសាស្ត្រមានចំនួន០៨កន្លែង, រមណីយដ្ឋានកែច្នៃធម្មជាតិ និងប្រវត្តិសាស្ត្រមានចំនួន០១កន្លែង, រមណីយដ្ឋានអេកូទេសចរណ៍ចំនួន០១កន្លែង និងរមណីយដ្ឋានកែច្នៃចំនួន០១កន្លែង ដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋានតាមរយៈការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងជួយដល់ប្រជាកសិករ និងប្រជាជននៅតំបន់នោះឱ្យមានការងារធ្វើ និងទទួលបានប្រាក់ចំណូលបន្ថែម។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាខេត្តបន្ទាយមានជ័យចំនួន៦.០០៦.០៧១នាក់ ក្នុងនោះភ្ញៀវទេសចរជាតិចំនួន៣.៨៨០.៩៥០នាក់ និងភ្ញៀវទេសចរអន្តរជាតិចំនួន២.១២៥.១២១នាក់ (ឆ្លងកាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែត)។

## ២.១០.វិស័យសាធារណការ និងផ្លូវលំ៖

ខេត្តមានបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ជាផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវលំជនបទ សម្រាប់បំណាងតភ្ជាប់ពីទីរួមខេត្ត ទៅ ក្រុង ស្រុក និងតំបន់ជនបទ។ បច្ចុប្បន្នខេត្តមានផ្លូវជាតិឆ្លងកាត់ខេត្តចំនួន៦ខ្សែ ប្រវែងសរុប៣៥០,៩៨គ.ម ផ្លូវខេត្តសរុបចំនួន១៥ខ្សែ ប្រវែង៣៥១,៥៣គ.ម ( ផ្លូវក្រាលកៅស៊ូ ប្រវែង១៥៣,៦១គ.ម និងផ្លូវក្រួស១៩៧,៩២គ.ម ) និងមានផ្លូវរថភ្លើងចំនួន១ខ្សែឆ្លងកាត់បម្រើឱ្យការដឹកជញ្ជូនទំនិញដ៏សំខាន់សម្រាប់សេដ្ឋកិច្ចជាតិ។ ខេត្តមានសំណង់ស្ពានជាច្រើនកន្លែងឆ្លងកាត់ស្ទឹង ( ដែលពីមុនមានតែចំនួន៦៤កន្លែងដល់បច្ចុប្បន្នមានរហូតដល់១០៤កន្លែង)។ ជាពិសេសថ្មីៗនេះ ការកសាងកំណាត់ផ្លូវប្រវែង៨៤,៧៤គ.ម មាន៤គម្រោង នៃគម្រោងធ្វើឱ្យប្រសើរឡើងវិញផ្លូវជាតិលេខ៥ សេរីសោភ័ណ-បាត់ដំបង ត្រូវបានបញ្ចប់ជាស្ថាពរ និងបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

## ២.១១.វិស័យអប់រំ៖

គិតមកដល់ឆ្នាំ២០២២ ខេត្តមានគ្រឹះស្ថានសិក្សាគ្រប់ភូមិសិក្សានៅទូទាំងខេត្ត ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈចំនួន៨២២កន្លែង និងគ្រឹះស្ថានសិក្សាឯកជននិងអង្គការចំនួន១៤០កន្លែង។ ក្រៅពីសាលាចំណេះទូទៅ ខេត្តមានសាកលវិទ្យាល័យចំនួន ៤កន្លែង គឺ៖

១.សាកលវិទ្យាល័យជាតិមានជ័យ, ២.សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME), ៣.សាកលវិទ្យាល័យឯកទេសនៃកម្ពុជា (CUS) និង៤.សាកលវិទ្យាល័យបៀលប្រាយ (BBU)។ ជាមួយនឹងសមិទ្ធផលខាងលើ រដ្ឋបាលខេត្តទទួលបាន អគារសិក្សាចំនួន២០៤ខ្នង ស្មើនឹង១.៦៣០បន្ទប់, ម៉ាស៊ីនដេរចំនួន៣៧០គ្រឿង, ម៉ាស៊ីនថតចម្លងចំនួន១១គ្រឿង, ម៉ាស៊ីនព្រីនធ័រ២០គ្រឿង, និងកុំព្យូទ័រ១១៤គ្រឿង ដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន**និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត**។ **ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានខេត្តបន្ទាយមានជ័យ បានផ្តល់អគារសិក្សាចំនួន៨០ខ្នង ស្មើនឹង៣៩៧បន្ទប់ ចែកចេញជាអគារសិក្សា បណ្ណាល័យ ទីចាត់ការ និងផ្ទះគ្រូ។

ក្នុងឆ្នាំសិក្សា( ២០១៨-២០២២ **សិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ក្នុងនោះសិស្សទទួលបាននិទ្ទេសA ដូចខាងក្រោម៖**

**+ឆ្នាំសិក្សា ២០១៧-២០១៨ = ១៣នាក់ ស្រី ០៣នាក់**

**+ឆ្នាំសិក្សា ២០១៨-២០១៩ = ២៥នាក់ ស្រី ១៥នាក់**

**+ឆ្នាំសិក្សា ២០១៩-២០២០ = ជាប់ស្ថាពរ១០០% គ្មាននិទ្ទេស**

**+ឆ្នាំសិក្សា ២០២០-២០២១ = ៩៩នាក់ ស្រី ៧០នាក់**

**+ឆ្នាំសិក្សា ២០១១-២០២២ = ៤៩នាក់ ស្រី ២៥នាក់**

## ២.១២.វិស័យសុខាភិបាលៈ

មូលដ្ឋានសុខាភិបាលក្នុងខេត្តបន្ទាយមានជ័យ មានស្រុកប្រតិបត្តិ ចំនួន០៦កន្លែង ( មង្គលបូរី,ប៉ោយប៉ែត ,ព្រះនេត្រព្រះ,ថ្មពួក,សិរីសោភ័ណ) មន្ទីរពេទ្យមាន០៩កន្លែង និងមណ្ឌលសុខភាពចំនួន៦៨កន្លែង និងមាន ប៉ុស្តិ៍សុខភាព ចំនួន១៣កន្លែង ។

***ព្រឹត្តិការណ៍២០កុម្ភៈ ឆ្នាំ២០២០*** បានធ្វើឱ្យមានការផ្ទុះឡើងការរីករាលដាលជំងឺកូវីដ១៩ នៅក្នុង ប្រទេសកម្ពុជា។ ទោះបីជាស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩ជាសកល ដែលមានផលប៉ះពាល់ ដល់សេដ្ឋកិច្ច និងសង្គម តែព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេច អគ្គមហាសេនាបតីតេជោ** ហ៊ុន សែនបានខិតខំកៀគរ ស្វែងរកវ៉ាក់សាំង ដើម្បីចាក់ជូនប្រជាពលរដ្ឋដោយឥត គិតថ្លៃ សំដៅបង្កើតភាពស៊ាំក្នុងសហគមន៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ **សម្តេច**បានផ្តល់វ៉ាក់សាំងស្រោច ស្រង់អាយុជីវិតរបស់ប្រជាជន ទាំងការគិតគូរលើកស្ទួយកម្រិតជីវភាពប្រជាពលរដ្ឋ តាមរយៈការអនុវត្តគោល នយោបាយ គាំពារសង្គម រួមនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បម្រើឲ្យការរីកចម្រើននៃសង្គមជាតិទាំងមូល។ ទន្ទឹមនេះខេត្តបន្ទាយមានជ័យ បានបន្តអនុវត្តយុទ្ធសាស្រ្តយ៉ាងម៉ឺងម៉ាត់ ជាលទ្ធផលស្ថិតិប្រជាពលរដ្ឋ ដែលបាន ចាក់វ៉ាក់សាំងរួមមានដូសទី១ បានចាក់វ៉ាក់សាំង **៦៦៩.២៦៣នាក់** ដូសទី២ **ចាក់បាន៥៨៧.៦១៤នាក់** ដូសទី៣ (ដូសជំរុញ) ចាក់បាន**៣៩៧,៨២៤នាក់** ដូសទី៤(រំលឹក)ចាក់បាន**១៨០.១៨៨នាក់** ដូសទី៥ ចាក់បាន **៤៣.៥៩៥**នាក់ និងដូសទី៦ ចាក់បាន**១.៦១៨នាក់**។

ចាប់តាំងពីថ្ងៃទី០៤កុម្ភៈឆ្នាំ២០២១ មកក្រសួងសុខាភិបាលប្រទេសកម្ពុជា បានប្រកាសចេញលិខិត អនុញ្ញាតស្តីពី ការប្រើប្រាស់វ៉ាក់សាំងការពារជំងឺកូវីដ១៩ដែលមានឈ្មោះថា Sino pharm COVID-19 ដែលផលិ តនៅសាធារណរដ្ឋប្រជាមានិតចិន។ ដោយមានការជឿជាក់ទៅលើប្រសិទ្ធភាពនៃវ៉ាក់សាំងនេះ រាជរដ្ឋាភិបាល បានខិតខំរកវ៉ាក់សាំងការពារជំងឺកូវីដ១៩បានទាន់ពេលវេលា ធ្វើការស្រោចជាដំបូងនៅរាជធានីភ្នំពេញ និង នៅតាមបណ្តាខេត្តជាបន្តបន្ទាប់ ជាពិសេសមន្ត្រីជួរមុខ អ្នកពាក់ព័ន្ធជាមួយយុទ្ធនាការប្រយុទ្ធនឹងជំងឺកូវីដនេះ។

ខេត្តបន្ទាយមានជ័យជាខេត្តមួយដែលទទួលយកបងប្អូនពលករវិលត្រឡប់ពីប្រទេសថៃប្រមាណ ជាង៧ម៉ឺននាក់ ដែលត្រូវវិលត្រឡប់មកស្រុកកំណើតនៅតាមខេត្តផ្សេងៗទាំង២៥រាជធានី ខេត្ត និងត្រូវស្នាក់នៅ ធ្វើចត្តាឡីស័ក១៤ថ្ងៃមុនបន្តដំណើរទៅកាន់ខេត្តកំណើតខ្លួនវិញ។ ក្នុងអំឡុងពេលនោះ គ្រប់ក្រុង ស្រុក ទូទាំង ខេត្ត គឺត្រូវយកសាលារៀន១ឬ២កន្លែង ធ្វើជាមណ្ឌលចត្តាឡីស័ក និងធ្វើជាមណ្ឌលព្យាបាលផងដែរ ដែល មានសរុបរហូតដល់ជាង២៤មណ្ឌលទូទាំងខេត្ត មណ្ឌលព្យាបាលកម្រិតស្រាល២០កន្លែង និងមណ្ឌល ព្យាបាលកម្រិតធ្ងន់០២កន្លែង។ មន្ត្រីរាជការទាំងស៊ីវិល ទាំងកងកម្លាំង បានរួមគ្នាបំពេញភារកិច្ចនៅតាម ចំណុចគោលដៅ ពោលគឺតាំងពីច្រកព្រំដែន រហូតដល់មណ្ឌលចត្តាឡីស័ក និងបន្តដឹកជញ្ជូនរហូតដល់ ខេត្តសាមី ក្រោយពីបានបញ្ចប់ចត្តាឡីស័ក ១៤ថ្ងៃឬអាចដល់២៨ថ្ងៃឬលើសពីនេះ ករណីការធ្វើតេស្តឃើញ អ្នកជាប់ពាក់ព័ន្ធមានមេរោគកូវីដ១៩។ បងប្អូនដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក គឺត្រូវបានដឹកជញ្ជូនទៅ តាមខេត្តសាមី ដោយរថយន្តកងទ័ព និងណែនាំឲ្យពួកគាត់បន្តធ្វើចត្តាឡីស័កនៅផ្ទះថែមទៀត មុននឹងចេញ ប្រកបរបរអាជីវកម្មប្រាស្រ័យទាក់ទង ជាមួយអ្នកដទៃបាន។

## ២.១៣.ស្ថានភាពនៃការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ៖

ខេត្តបន្ទាយមានជ័យរយៈពេល៥ឆ្នាំនេះ វិស័យសំណង់មានការរីកលូតលាស់ខ្លាំង ការសាងសង់អគារកម្ពស់ចាប់ពី៥ជាន់ឡើងក្នុងនោះមាន៖ សណ្ឋាគារចំនួន០៣កន្លែង អគារស្នាក់នៅចំនួន២៩កន្លែង ផ្ទះសំណាក់ចំនួន០១កន្លែង ផ្ទះល្វែងចំនួន៥៧កន្លែង អគារការិយាល័យចំនួន០១កន្លែង សាលារៀនចំនួន៣កន្លែង អគារសាធារណៈ ចំនួន០១កន្លែង បន្ទប់ជួលចំនួន០២កន្លែង និងធនាគារចំនួន០២កន្លែង។

ការអភិវឌ្ឍវិស័យអចលនទ្រព្យបច្ចុប្បន្នកំពុងរីកចម្រើនខ្លាំង គម្រោងដីឡូរយៈពេល៥ឆ្នាំមកនេះ មានចំនួន ១៦៨គម្រោង ស្មើនឹង ៣៦.១២០ល្វែង។

រដ្ឋបាលខេត្តបាននិងកំពុងរៀបចំផែនការប្រើប្រាស់ដីខេត្តបន្ទាយមានជ័យ គាំទ្រដោយធនាគារADB និងកំពុងរៀបចំប្លង់គោលប្រើប្រាស់ដីក្រុងសិរីសោភ័ណ និងធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីក្រុងប៉ោយប៉ែតដោយគណៈកម្មាធិការ រៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ គាំទ្រដោយ ADB កសាងផែនការប្រើប្រាស់ដីថ្នាក់ឃុំចំនួន០៣ឃុំ នៅក្នុងស្រុកមង្គលបូរី ស្រុកអូរជ្រៅ និងស្រុកព្រះនេត្រព្រះ និងអនុម័តបានចំនួន០១ឃុំ ( ឃុំឫស្សីក្រោក ស្រុកមង្គលបូរី )។

***ការងារសំណង់៖*** បានពង្រឹងការអនុវត្តវិធានការសំណង់ និងត្រួតពិនិត្យការអនុញ្ញាតសាងសង់ដោយបានចេញលិខិតអនុញ្ញាតសាងសង់មានចំនួន១.២១៨គម្រោង មានផ្ទៃក្រឡាសរុប៤៤៦.៥២២,៤១ ម$^{២}$ និងរបងចំនួន ៩.៥៣២,២២ម ដែលមានទុនវិនិយោគប្រមាណ ៤៣៥.៤៨៤.៨៤៦,៦ ដុល្លារអាមេរិក។

បានអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈប្រព័ន្ធ និងដាច់ដោយដុំ ក្នុងនោះការចុះបញ្ជីជាប្រព័ន្ធ បានបញ្ចូលទិន្នន័យក្បាលដីចំនួន១៧៧.០៣៣ក្បាលដី និងបណ្ណចុះហត្ថលេខារួចចំនួន១៤២.៩៧៧ប័ណ្ណ ក្នុងនោះមានក្បាលដីឯកជនចំនួន៨៧.០៥០ប័ណ្ណ ដីសាធារណៈរបស់រដ្ឋចំនួន១.៦៥៥ប័ណ្ណ និងដីគរុភណ្ឌវត្តចំនួន ៣៣ប័ណ្ណ។ ដោយឡែកការចុះបញ្ជីលើកដំបូងដាច់ដោយដុំ បានចំនួន៨២៦ប័ណ្ណ ក្បាលដីឯកជនចំនួន ៧៩១ប័ណ្ណ ក្បាលដីសាធារណៈរបស់រដ្ឋចំនួន២៩ប័ណ្ណ ( មាន១១ប័ណ្ណដីតំបន់ព្រៃលិចទឹក ) និងដីគរុភណ្ឌវត្តចំនួន០៦ប័ណ្ណ។

- **ការងារដោះស្រាយវិវាទដីធ្លី÷** ការសម្របសម្រួល ដោះស្រាយវិវាទដីធ្លី រដ្ឋបាលខេត្តបានប្រើប្រាស់យន្តការចំនួន២÷ **(ទី១)គណៈកម្មការចម្រុះខេត្តដោះស្រាយវិវាទដីធ្លី** សរុបមានករណីវិវាទដីធ្លីចំនួន១១០ករណី បានដោះស្រាយបញ្ចប់ចំនួន៥១ករណី ចំនួននៅសល់ជាក់ស្តែង៥៩ករណីក្នុងនោះករណីវិវាទស្ថិតក្នុងសមត្ថកិច្ចថ្នាក់ជាតិចំនួន០៦ករណី តុលាការ១៦ករណី ខេត្តចំនួន៥២ករណី មន្ទីរដនសស១៣ករណី និងក្រុង ស្រុក០៨ករណី និង **(ទី២) គណៈកម្មការសុរិយោដីខេត្ត** ករណីវិវាទចំនួន **៤៥ករណី** ស្ថិតនៅលេខាធិការដ្ឋាន កំពុងដោះស្រាយ។ បន្ថែមលើសពីនេះ ខេត្តបន្ទាយមានជ័យបានបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងរយៈពេល៥ឆ្នាំនេះ សម្រេចបានលើផ្ទៃដីសរុប ចំនួន ៥១.០៥២.១៩២ ម$^{២}$ និងបានយកមកប្រើប្រាស់ជាដីកសិកម្ម និងដីលំនៅឋាន។
- **ការងារសម្បទានដីសង្គមកិច្ច** បានចុះវាស់វែងបែងចែកដីជាឡូតិ៍នៃដីសម្បទានសង្គមកិច្ច(២២២) បានចំនួន១.៨១៩,៦១ហិកតា សម្រាប់ចែកជូនអតីតយុទ្ធជន និងប្រជាពលរដ្ឋ។
- **ការងារព្រៃលិចទឹក៖ ផ្ទៃដីព្រៃលិចទឹកសរុបមានចំនួន ១២ ២៧៩,១៨**ហិកតានិងមាន៤៨ចំណុចនិយាមកាសហគមន៍នេសាទមានចំនួន១៩សហគមន៍ ស្រះជម្រកត្រីសហគមន៍មានចំនួន៥៧កន្លែង កន្លែងអភិរក្ស

ត្រីមេពូជសហគមន៍មានចំនួន៤២កន្លែង បានស្នើសុំគោលការណ៍ កាត់ឆ្វៀលដីចេញពីតំបន់២ បញ្ចូលក្នុងតំបន់១មានចំនួន១០ភូមិ(ដូនឡឹក ចែកអង្គរ ស្រែព្រៃថ្មដប់ ក្បាលក្របី ស្រះឈូក សំបួរ ស្ទឹងកំបុត កាបៅ កំពង់ក្រសាំង ) មានទំហំផ្ទៃដីសរុបទំហំ៣១៦.០២ហិកតា។ ក្នុងនោះរាជរដ្ឋាភិបាលបានសម្រេចកែសម្រួល ផ្ទៃដីបង្កបង្កើនផលចេញពីតំបន់៣មកតំបន់២ចំនួន ៣ ៤៤១ហិកតា ១០អា រួមបញ្ចូលទាំងផ្ទៃដីបម្រុងទុកចំនួន១០% និងផ្ទៃដីសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធចំនួន២០% ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងបានកែសម្រួលផ្ទៃដីលំនៅឋាន ទំហំ៣១៦ហិកតា ០២អា ចេញពីតំបន់២ បញ្ចូលមកតំបន់១ ស្ថិតក្នុងភូមិសាស្ត្រស្រុកចំនួន២ គឺស្រុកព្រះនេត្រព្រះ និងស្រុកមង្គលបូរី។

## ២.១៤.វិស័យអគ្គិសនី ទឹកស្អាត និងអនាម័យ៖

ខេត្តបន្ទាយមានជ័យ បានទទួលការផ្គត់ផ្គង់ថាមពលពីខ្សែបញ្ជូនជាតិ១១៥គីឡូវ៉ុល ពីប្រទេសថៃ២៣០គីឡូវ៉ុល ហើយមានប្រភពថាមពលដើរដោយពន្លឺព្រះអាទិត្យ ដែលមានអានុភាព៣០មេហ្កាវ៉ាត់បន្ថែមទៀត ព្រមទាំងមានសេវាករចែកចាយអគ្គីសនីសរុបចំនួន២៦អាជ្ញាប័ណ្ណ។ តម្រូវការប្រើប្រាស់ក្នុងខេត្តសរុប១១០មេកាវ៉ាត់។ គ្រួសារប្រជាពលរដ្ឋខេត្តមានចំនួន៩៩%មានអគ្គីសនីប្រើប្រាស់។ សូមគូសបញ្ជាក់ដែរថា ខេត្តកំពុងធ្វើការពង្រីកការតភ្ជាប់បណ្តាញអគ្គិសនីបន្ថែមទៀតដល់មូលដ្ឋានភូមិ ឃុំ ពិសេសនៅតំបន់ជនបទ។

ចំពោះសេវាករទឹកស្អាតរបស់ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតខេត្តបន្ទាយមានជ័យ អនុវត្តការងារផ្គត់ផ្គង់ទឹកស្អាតដល់ក្រុង ស្រុក ស្មើនឹង៦១/៦៥ឃុំ សង្កាត់ ស្មើនឹង៦៤១/៦៥៩ភូមិ ដែលជាដែនសេវាកម្មអាជ្ញាប័ណ្ណ របស់អង្គភាពដែលមានប្រជាជនទទួលបានសេវាទឹកស្អាតបាន៧៦%។

ចំពោះអត្រាគ្របដណ្តប់អនាម័យទូទាំងខេត្តគិតត្រឹមឆ្នាំ២០២២បាន៨៩% ក្នុងនោះបានប្រកាសភូមិ ឃុំ បញ្ចប់ការបន្ទោសបង់ពាសវាលពាសកាលចំនួន១០៣ភូមិ ស្មើនឹង៣ឃុំ។

## ២.១៥.វិស័យព័ត៌មាន៖

ការងារព័ត៌មានបានធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុមានចំនួន២៣ស្ថានីយ៍ និងស្ថានីយ៍ទូរទស្សន៍ខេត្តមាន១១ស្ថានីយ៍ ដោយផ្តោតការយកចិត្តទុកដាក់ លើកកម្ពស់អភិបាលកិច្ចល្អ និងកិច្ចអភិវឌ្ឍន៍សង្គមជាតិ ដោយគោរព និងអនុវត្តតាមគោលការណ៍វិជ្ជាជីវៈ បានផលិតកម្មវិធី និងផ្តល់ព័ត៌មានត្រឹមត្រូវ ទាន់ពេលវេលា ធ្វើជាស្ពានចំលងនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ជូនដល់ប្រជាពលរដ្ឋ និងពីប្រជាពលរដ្ឋទៅរាជរដ្ឋាភិបាល និងផ្តល់ឱកាសដល់អ្នកស្តាប់បានចូលរួមសម្តែងនូវមតិ ចំណាប់អារម្មណ៍ ពីតម្រូវការចាំបាច់ ពីបញ្ហាប្រឈមផ្សេងៗ ដែលទាក់ទងនិងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍន៍សង្គមជាតិ ដោយបានជួបជជែក ពិភាក្សាជាមួយវាគ្មិន ជាមន្ត្រីរាជរដ្ឋាភិបាល អាជ្ញាធរគ្រប់ថ្នាក់ អង្គការដៃគូសង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋ ចែករំលែកនូវបទពិសោធន៍ បង្កើតនូវចំណេះដឹង ក្នុងការរកដំណោះស្រាយរួមគ្នា គោរព និងអនុវត្តន៍តាមគោលការណ៍នៃច្បាប់ ប្រកបដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងឆ្នាំ២០១៨ ដោយបានការយកចិត្តទុកដាក់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន បានបំពាក់ម៉ាស៊ីនផ្សាយទូរទស្សន៍ ដែលមានកំលាំងផ្សាយចេញ 5KW (អាចទទួលមើលបានដល់ប្រជាពលរដ្ឋគ្រប់ ស្រុក-ក្រុង ទូទាំង ខេត្តបន្ទាយមានជ័យ) រហូតមកដល់បច្ចុប្បន្ននេះ។

## III . ទិសដៅការងារបន្ត

- ជំរុញការផ្តល់វ៉ាក់សាំងកូវីដ១៩(ដូសជំរុញ)ជូនបងប្អូនប្រជាពលរដ្ឋគ្រប់វ័យឲ្យបានគ្រប់ៗគ្នា។
- ជំរុញការផ្តល់សេវាតាមច្រកចេញចូលតែមួយឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងទាន់ពេលវេលា ។

- ជំរុញវិស័យកសិកម្ម កសិឧស្សាហកម្ម បែបបច្ចេកទេស ដីតិចទទួលផលច្រើន មានគុណភាព និងមានទីផ្សារ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។
- ជំរុញវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ដោយលើកទឹកចិត្តឱ្យមានការវិនិយោគបន្ថែម សម្រាប់រោងចក្រ សហគ្រាស ដើម្បីបង្កើនការងារជូនប្រជាពលរដ្ឋ និងកាត់បន្ថយការធ្វើចំណាកស្រុក។
- ជំរុញការថែរក្សាធនធានធម្មជាតិ ដូចជាតំបន់អភិរក្សព្រៃឈើ អភិរក្សជលផល តំបន់ការពារធនធានធម្មជាតិ តំបន់ព្រៃលិចទឹក ដែលជាជម្រកសត្វ និងត្រី ព្រមទាំងចូលរួមក្នុងការទប់ស្កាត់បំរែបំរួលអាកាសធាតុ និងគ្រោះមហន្តរាយដោយគ្រោះធម្មជាតិនានា។
- ជំរុញការផ្តល់អគ្គិសនីលើភូមិទូទាំងខេត្ត។
- ជំរុញការកសាង កែលំអ ថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទាំងផ្លូវជាតិ ផ្លូវខេត្ត ផ្លូវជនបទ ដើម្បីឱ្យទីក្រុង និងជនបទមានទំនាក់ទំនងគ្នាល្អលើផ្នែកសេដ្ឋកិច្ច និងសង្គម។
- ជំរុញការកសាងប្រព័ន្ធភ្លឺ ប្រឡាយ និងកែលំអប្រព័ន្ធស្រោចស្រពបន្ថែម បំរើឱ្យវិស័យកសិកម្មដែលកំពុងមានការរីកចម្រើន និងការបង្កើនផ្ទៃដីដាំដុះរបស់ប្រជាពលរដ្ឋ ។
- ជំរុញការកែលំអទីប្រជុំជនខេត្ត រក្សាអនាម័យបរិស្ថាន ។
- បង្កើន និងពង្រឹងការគ្រប់គ្រង ប្រើប្រាស់ដីធ្លីដោយជំរុញការចុះបញ្ជីដីធ្លី ផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលធានាបាននូវការប្រើប្រាស់ដីរដ្ឋ ដីឯកជនស្របច្បាប់ ដែលឈានទៅកាត់បន្ថយទំនាស់ដីធ្លី ព្រមទាំងបង្កើនចំណូលសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។
- បន្តជំរុញការផ្សព្វផ្សាយពីគោលនយោបាយភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព ដើម្បីទប់ស្កាត់ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ភាពអសកម្មក្នុងសង្គមនានា និងរឹតបន្តឹងច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនឯកឧត្តម គណៈអធិបតី ឯកឧត្តម លោកជំទាវ លោកឧត្តមសេនីយ៍ លោក លោកស្រីទាំងអស់ ***សូមទេវតាឆ្នាំថ្មី ប្រោសព្រំពរជ័យ សិរីសួស្តី សុភមង្គល វិបុលសុខ គ្រប់ប្រការ និងជោគជ័យគ្រប់ភារកិច្ច ជានិច្ចនិរន្តរ៍***។

**សូមអរគុណ !**